# ទម្រង់ពាក្យស្នើសុំ
# «មូលនិធិដំឡើងស្នាដៃថ្មី ឆ្នាំ ២០២៤»
## ស្នាដៃសិល្បទស្សនីយភាព ក្រោមមូលបទ «សិល្បៈនិងសង្គម»

សិល្បៈខ្មែរអមតៈ

ព័ត៌មានសំខាន់ៗ

- កាលបរិច្ឆេទកំណត់ឈប់ទទួលពាក្យ **ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៤ វេលាម៉ោង ៥:០០ ល្ងាច**
- ពាក្យស្នើសុំអាចផ្ញើមកកាន់អ៊ីម៉ែល **samath@cambodianlivingarts.org**
  ឬយកទៅដាក់ផ្ទាល់នៅការិយាល័យអង្គការសិល្បៈខ្មែរអមតៈ ដែលមានអាសយដ្ឋាន **ផ្ទះលេខ១៣E ផ្លូវលេខ៨៣០ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ**
- វេទិកាសំណួរចម្លើយតាមអនឡាញ នឹងចាប់ពី **ម៉ោង ៥:៣០ ដល់ ៧:០០ ល្ងាច នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០២៤** តាមរយៈតំណភ្ជាប់ហ្សូមខាងក្រោមនេះ៖
  https://us02web.zoom.us/j/84133241789?pwd=ZFU2V20xdG8xM1VwR2FPeElPR2VHUT09
  **Meeting ID:** 841 3324 1789 **Passcode:** 459289
- ដើម្បីចូលរួម អ្នកអាចចុះឈ្មោះទុកជាមុនតាមតំណភ្ជាប់នេះ https://forms.gle/fUReFgrz5uPXZeXP8
- សម្រាប់ព័ត៌មានលម្អិត **សូមមើលទិដ្ឋភាពទូទៅនៃកម្មវិធី**

## ១ ៖ ព័ត៌មានអំពីអ្នក

### ១.១ ព័ត៌មានលម្អិតរបស់អ្នក

សូមបំពេញព័ត៌មានខាងក្រោម ៖

| | |
|---|---|
| នាមត្រកូល: | |
| នាមខ្លួន: | |
| ឈ្មោះហៅក្រៅ: | |
| ភេទ / សព្វនាម: | |
| សញ្ជាតិ: | |
| អ៊ីម៉ែល: | |
| លេខទូរស័ព្ទ: | |
| អាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន: | |

## ១.២ ការណែនាំសង្ខេបរបស់អ្នក

សូមណែនាំជាសង្ខេបអំពីខ្លួនអ្នក

<u>ប្រវែងនៃការសរសេរៈ ១០ទៅ១៥ បន្ទាត់</u>

១.៣ សូមផ្តល់ប្រវត្តិរូបសង្ខេបរបស់អ្នក

តើអ្នកបានភ្ជាប់ប្រវត្តិរូបសង្ខេបរបស់អ្នកមកជាមួយនឹងពាក្យស្នើសុំដែរឬទេ?

| | |
|---|---|
| សូមសរសេរ បាទ/ចាំ ឬ ទេ | |

## ២ ៖ លក្ខណៈសម្បត្តិ

សូមបញ្ជាក់ថាអ្នកមានលក្ខណសម្បត្តិដូចខាងក្រោម៖

| លក្ខណៈសម្បត្តិ | សូមសរសេរ «បាទ/ចាំ» ឬ «ទេ» |
|---|---|
| មានសញ្ជាតិខ្មែរ និង កំពុងស្នាក់នៅប្រទេសកម្ពុជា | |
| មានពេលគ្រប់គ្រាន់សម្រាប់ចូលរួមកម្មវិធីតាមកាលបរិច្ឆេទទាំងអស់ដែលបាន កំណត់នៅក្នុងទិដ្ឋភាពទូទៅនៃកម្មវិធី | |
| មានឆន្ទៈក្នុងការចូលរួមសហការ និងការតាំងចិត្តខ្ពស់និងពេលវេលាគ្រប់គ្រាន់ក្នុងមូលនិធិដំឡើងស្នាដៃថ្មី | |
| សិល្បករ និងប្រតិបត្តិករសិល្បៈនិងវប្បធម៌សមាជិកក្នុងសហគមន៍សិល្បៈ | |
| | |

## ៣ ៖ អំពីបទពិសោធន៍

៣.១ ចូរនិយាយអំពីបទពិសោធន៍របស់អ្នកក្នុងការដំឡើងស្នាដៃថ្មី ។ បើសិនជាអ្នកធ្លាប់បានអនុវត្តនិងគ្រប់គ្រងការដំឡើងស្នាដៃថ្មីពីមុនមក សូមផ្តល់ជាឧទាហរណ៍ខ្លះៗ និងសូមប្រាប់អំពីព័ត៌មានខ្លះៗ ដូចជាការប្រើប្រាស់ថវិកា រយៈពេលដែលអ្នកបានចំណាយនៅលើការដំឡើងស្នាដៃ និងចំនួនមនុស្សប៉ុន្មាននាក់ដែលពាក់ព័ន្ធក្នុងដំណើរការមួយនេះ ។ ប្រសិនបើវាជាការដំឡើងស្នាដៃដំបូងរបស់អ្នក សូមប្រាប់ពីបទពិសោធន៍ផ្សេងៗ ដែលអ្នកមាន (ឧទាហរណ៍ នៅសាលា នៅក្នុងសហគមន៍ ឬជាអ្នកស្ម័គ្រចិត្តនានា ដែលពាក់ព័ន្ធជាមួយនឹងសិល្បទស្សនីយភាព ជាពិសេសការដំឡើងស្នាដៃថ្មី) ដែលអ្នកគិតថាបានជួយដល់ការកសាងជំនាញ និងបទពិសោធន៍ដែលអ្នកគួរតែប្រើដើម្បីដំឡើងស្នាដៃថ្មីរបស់អ្នក ។

ប្រវែងនៃការសរសេរ: ២០ទៅ៣០ បន្ទាត់

៣.២ តើអ្នកមានចំណុចខ្លាំងអ្វីខ្លះ ដើម្បីយកមកអនុវត្តការដំឡើងស្នាដៃថ្មីនេះ? ប្រសិនបើអ្នកមិនធ្លាប់ទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តការដំឡើងស្នាដៃពីមុនមកទេ  សូមជួយប្រាប់អំពីចំណុចខ្លាំងរបស់អ្នកខ្លះៗ ដែលអ្នកនឹងយកមកប្រើដើម្បីគ្រប់គ្រងការដំឡើងស្នាដៃនេះ។

<u>ប្រវែងនៃការសរសេរ: ១០ទៅ១៥ បន្ទាត់</u>

៣.៣ តាមបទពិសោធន៍របស់អ្នកនៅក្នុងការដំឡើងស្នាដៃថ្មី ឬជាផ្នែកមួយនៅក្នុងការដំឡើងស្នាដៃ។ តើអ្នកមានភាពប្រឈមអ្វីខ្លះ? ប្រសិនបើអ្នកមិនធ្លាប់ដំឡើងស្នាដៃពីមុនមកទេ សូមអ្នកជួយប្រាប់ថាតើភាពប្រឈមអ្វីខ្លះដែលអ្នករំពឹងថានឹងជួប។

<u>ប្រវែងនៃការសរសេរ:  ១០ទៅ១៥ បន្ទាត់</u>

| |
|---|
| |

៣.៤ ជម្រើសៈ ប្រសិនបើអ្នកចង់ប្រាប់អំពីឧទាហរណ៍ខ្លះៗទាក់ទងនឹងការដំឡើងស្នាដៃថ្មីពីមុន ដែលអ្នកធ្លាប់ធ្វើ សូមផ្តល់តំណភ្ជាប់ ឬ ឯកសារ (មិនឱ្យលើសពី ៣) នៅក្នុងពាក្យស្នើសុំនេះ។

| | |
|---|---|
| តើមានឯកសារប៉ុន្មានដែលអ្នកបានភ្ជាប់មកជាមួយ? | |
| សូមដាក់តំណភ្ជាប់នៅទីនេះ (បើមាន) ៖ | |

## ភាគ ៤ ៖ ស្នាដៃរបស់អ្នក

៤.១ ចំណងជើងស្នាដៃ (អាចជាចំណងជើងបណ្តោះអាសន្ន)

| |
|---|
| |

៤.២ សូមសង្ខេបពីស្នាដៃស្នើសុំរបស់អ្នក

នៅត្រង់ចំណុចនេះ អ្នកគួរតែផ្តល់ព័ត៌មានសំខាន់ៗដូចជា៖ ទីតាំង គម្រោង ពេលវេលា ហើយនរណាខ្លះជាប់ពាក់ព័ន្ធក្នុងស្នាដៃ ដែលអាចរាប់បញ្ចូលនូវចំណុចខាងក្រោម៖

- ទម្រង់សិល្បៈ
- សូមពិពណ៌នាដោយសង្ខេបពីចំនួននិងប្រភេទសិល្បករដែលអ្នកនឹងសហការ
- ប្រសិនបើស្នាដៃរបស់អ្នកមានជាសាច់រឿងរួចហើយ ឬក៏ជាស្នាដៃថ្មីកំពុងអភិវឌ្ឍ សូមចែករំលែកពីគោលគំនិតនិង តម្រូវការនៃការអភិវឌ្ឍបន្ថែមនោះ (សិល្បៈខ្មែរអមតៈយល់ជាក់ច្បាស់ថាសាច់រឿងនេះ អាចនឹងមានការប្រែប្រួលអំឡុងពេលបង្កើត)
- ប្រសិនបើស្នាដៃរបស់អ្នកមានត្រឹមតែគោលគំនិត (CONCEPT) នៅឡើយ សូមរៀបរាប់អំពីគោលគំនិតនោះ

<u>ប្រវែងនៃការសរសេរ៖ ២០ទៅ៣០ បន្ទាត់</u>

៤.៣ ប្រាប់ពីមូលហេតុដែលអ្នកចង់បង្កើត/អភិវឌ្ឍបន្ថែមនិងបង្ហាញស្នាដៃថ្មីជាមួយមូលនិធិជំនឿងស្នាដៃថ្មី ឆ្នាំ ២០២៤ នេះ៖

- តើគោលដៅរបស់អ្នកសម្រាប់មូលនិធិនេះគឺជាអ្វី? តើលទ្ធផលអ្វីដែលអ្នកចង់ឃើញ? តើកត្តាអ្វីជំរុញឱ្យអ្នកធ្វើគម្រោងនេះឡើង?
- មូលហេតុដែលអ្នកគិតថាពេលនេះជាឱកាសនិងពេលវេលាដ៏សក្តិសមសម្រាប់អ្នកក្នុងការបង្ហាញស្នាដៃនេះ?

ប្រវែងនៃការសរសេរ: ២០ទៅ៣០ បន្ទាត់

៤.៤. សូមពន្យល់ថាតើស្នាដៃរបស់អ្នកឆ្លើយតបទៅនឹងមូលបទ «សិល្បៈនិងសង្គម» យ៉ាងដូចម្តេច ។ ប្រាប់ពីចំណុចដែលអ្នកយល់ថាស្នាដៃអ្នកគួរតែត្រូវបានជ្រើសរើសដើម្បីទទួលបានមូលនិធិនេះ ។ តើវានឹងមានការជះឥទ្ធិពលដល់ការអភិវឌ្ឍសង្គមនិងសិល្បៈដោយរបៀបណា? តើនរណាខ្លះជាអ្នកចូលរួមសហការរបស់អ្នកសម្រាប់ដំណើការដំឡើងស្នាដៃនេះ? ចូរពិពណ៌នាអំពីពួកគេ ឧ. និយាយអំពីអាយុ ប្រភេទការងារ របស់ពួកគេ អត្តសញ្ញាណវប្បធម៌របស់ពួកគេ? តើពួកគេមកពីណា? តើអ្នកមានទំនាក់ទំនងអ្វីជាមួយពួកគេ?

<u>ប្រវែងនៃការសរសេរៈ ២០ទៅ៣០ បន្ទាត់</u>

៤.៥. សកម្មភាពចម្បងៗនិងគម្រោងពេលវេលារបស់អ្នក

សូមប្រើប្រាស់តារាងខាងក្រោម ដើម្បីប្រាប់អំពីសកម្មភាពចម្បងៗ ដែលអ្នកគ្រោងនឹងអនុវត្តនៅក្នុងគម្រោងនៃការដំឡើងស្នាដៃរបស់អ្នក និងកាលបរិច្ឆេទជាក់លាក់ដែលអ្នកអនុវត្តសកម្មភាពទាំងនោះ។

**សម្គាល់៖** ប្រសិនបើស្នាដៃរបស់អ្នកត្រូវបានជ្រើសរើស អ្នកនៅមានឱកាសកែសម្រួលផែនការរបស់អ្នកមុនពេលចុះកិច្ចសន្យា។

- អ្នកអាចបន្ថែមឬលុបបន្ទាត់ជួរដេកតាមតម្រូវការ ។
- ចូរព្យាយាមសរសេរមួយឬពីរល្បះ ក្នុងមួយ 'សកម្មភាព' ។ ឧ.
    - រៀបចំការធ្វើដំណើរស្រាវជ្រាវបន្ថែមទៅលើស្នាដៃរបស់អ្នក
    - ជួបជុំក្រុមដើម្បីពន្យល់ស្នាដៃរបស់អ្នកទាំងមូល
    - រយៈពេលសម (សមរៀងរាល់ថ្ងៃសៅរ៍និងអាទិត្យប្រហែល ៣ ម៉ោង) រយៈពេលបញ្ចប់និងពេលវេលាដាក់បង្ហាញស្នាដៃ ។

**បញ្ជាក់៖** អ្នកទទួលបានមូលនិធិ ត្រូវបញ្ជាក់ពីកាលបរិច្ឆេទនៃការអនុវត្តការដំឡើងស្នាដៃយ៉ាងតិចបំផុតរយៈពេល ៣ ខែ ជាចាំបាច់ ។

| សកម្មភាព | ចាប់ផ្តើម (ខែឆ្នាំ) | បញ្ចប់ (ខែឆ្នាំ) |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

| | | |
|---|---|---|
| | | |
| | | |
| | | |

៤.៦. គម្រោងថវិកាសម្រាប់ដំណើរការដំឡើងស្នាដៃ

សូមប្រើតារាងខាងក្រោមដើម្បីបង្ហាញពីថវិកាប៉ាន់ស្មានសម្រាប់គម្រោងនៃការដំឡើងស្នាដៃថ្មី ។

- ចូរប្រាប់ពីចំណាយទៅតាមប្រភេទខ្ទង់ចំណាយ ។ ប្រភេទខ្ទង់ចំណាយគម្រូខ្លះ ដែលអ្នកអាចប្រើមានដូចខាងក្រោម ៖
    - ចំណាយសម្រាប់អ្នកប្រឹក្សាយោបល់ (១ ០០០ ដុល្លា)
    - ចំណាយសម្រាប់សិល្បករនិងក្រុមការងារ
    - ការអភិវឌ្ឍគោលគំនិតនិងធាតុផ្សេងៗនៃផលិតកម្ម ដូចជា៖ សំលៀកបំពាក់ និងការរៀបចំតុបតែងឈុតឆាក (props, and set design)
    - ការស្រាវជ្រាវ សិក្ខាសាលា និវេសនដ្ឋាន
    - ការធ្វើដំណើរ ការស្នាក់នៅ និងការហូបចុក
    - ការជួលកន្លែង/ទីតាំង ឧបករណ៍និងសម្ភារៈ
- អាចបន្ថែមជួរតារាង បើត្រូវការ
- មិនចាំបាច់ដាក់ខ្ទង់ចំណាយដែលមិនពាក់ព័ន្ធ
- សូមប្រើតារាងខាងក្រោមដើម្បីបង្ហាញពីថវិកាប៉ាន់ស្មានសម្រាប់គម្រោងមូលនិធិ និងការគណនាខ្ទង់ចំណាយទាក់ទងនឹងដំណើរការនៃការបង្កើតស្នាដៃរបស់អ្នក
- សូមបន្ថែមបន្ទាត់ជួរដេកតាមតម្រូវការ

| ប្រភេទខ្ទង់ចំណាយ | លម្អិតពីការចំណាយ | ចំនួន (ដុល្លារ) |
|---|---|---|
| | | |
| | | |
| | | |

| | | |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | សរុប | |

## ផ្នែកទី ៥ ៖ អ្នកប្រឹក្សាយោបល់ផ្នែកសិល្បៈ

---

៥.១ ចូររៀបរាប់អំពីអ្នកប្រឹក្សាយោបល់ផ្នែកសិល្បៈ ។ ហេតុអ្វីបានជាអ្នកជ្រើសយកគាត់ជាអ្នកផ្តល់យោបល់ផ្នែកសិល្បៈ (សូមរៀបរាប់ពីលក្ខណៈសម្បត្តិខ្លះៗរបស់គាត់និងតម្រូវការការគាំទ្ររបស់អ្នកដែលអាចរួមមាន៖ តើគាត់ជានរណា បទពិសោធន៏នៃការធ្វើជាអ្នកប្រឹក្សាសិល្បៈពីមុន ភាពស៊ីគ្នានៃចំណេះ និងជំនាញទៅនឹងគម្រោងដែលអ្នកស្នើសុំផែនការដែលអ្នកគ្រោងនឹងធ្វើការជាមួយគាត់ និងតួនាទីដែលគាត់នឹងត្រូវគាំទ្រក្នុងគម្រោងនេះ ។ល។)

**បញ្ជាក់៖** មូលនិធិចំនួន ១០០០ ដុល្លារ ដែលជាមូលនិធិរួមរបស់មូលនិធិដំឡើងស្នាដៃថ្មីនេះ នឹងត្រូវបែងចែកផ្តល់ជូនទៅកាន់ អ្នកប្រឹក្សាយោបល់ផ្នែកសិល្បៈក្នុងដំណើរការដំឡើងស្នាដៃថ្មីរបស់អ្នកនេះ ។
<u>ប្រវែងនៃការសរសេរ: ១០ទៅ១៥ បន្ទាត់</u>

| |
|---|
| |

## ផ្នែកទី ៦ ៖ ការបង្ហាញស្នាដៃ

៦.១ តើអ្នកនឹងបង្ហាញស្នាដៃរបស់អ្នកនៅពេលណា ថ្ងៃណា ខែណា? តើនរណាខ្លះជាទស្សនិកជនគោលដៅសម្រាប់ការបង្ហាញស្នាដៃរបស់អ្នក? ហេតុអ្វីបានជាអ្នកគិតថាពួកគេសំខាន់នៅក្នុងការបង្ហាញស្នាដៃរបស់អ្នក? ចូរពិពណ៌នាអំពីពួកគេ ។

**បញ្ជាក់៖** អ្នកត្រូវតែបញ្ចប់ការដំឡើងស្នាដៃរបស់អ្នក នៅពាក់កណ្តាល ខែធ្នូ ឆ្នាំ២០២៤

ប្រវែងនៃការសរសេរ: ១០ទៅ១៥ បន្ទាត់

សូមអរគុណចំពោះចំណាប់អារម្មណ៍លើកម្មវិធីនេះ!